**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ-អ.ជ.ស.ដ/អ.ជ.ត.ក ( )

ភាគីដាក់ឯកសារ: សហមេធាវីរបស់ អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2013, 10:12
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី សុំថតខ្សែអាត់សំឡេង និង/ឬវីដេអូ នៅពេល អៀង សារី ស្ថិតនៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងសំណើសុំការពិចារណារួមគ្នាលើបណ្ដឹងសាទុក្ខនេះ និងបណ្ដឹងសាទុក្ខប្រឆាំងនឹងការសម្រេចដោយផ្ទាល់មាត់បដិសេធសិទ្ធិរបស់គាត់ ដែលត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនថតវីដេអូគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមក្រោមសាលសវនាការ** (E238/9/1/1)

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្ដម

លោក Michael G. KARNAVAS

ផ្ញើជូន៖

**អង្គជំនុំជម្រះតុលាការកំពូល**

ឯកឧត្ដម គង់ ស្រីម

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម ម៉ុង មុនីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមតាមវិធាន១០៦ និង តាមការណែនាំរបស់មន្ត្រីច្បាប់/ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល[1] ឥឡូវនេះសូមដាក់ការជូនដំណឹងរបស់គាត់អំពីបណ្តឹងសារទុក្ខប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់មេធាវីការពារក្តីឲ្យ អៀង សារី សុំថតខ្សែរអាត់សំឡេង និង/ឬវីដេអូរបស់លោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ (“សេចក្តីសម្រេចដែលរងការជំទាស់”)[2] និងស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណាបណ្តឹងសារទុក្ខនេះ នៅក្នុងទម្រង់រួមគ្នាជាមួយនឹងបណ្តឹងសារទុក្ខដែលមិនទាន់ដោះស្រាយ ប្រឆាំងនឹងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសិទ្ធិរបស់គាត់ត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឲ្យថតវីដេអូគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ[3]។ ការជូនដំណឹង និងសំណើនេះ ត្រូវធ្វើឡើងសម្រាប់ហេតុផលខាងក្រោម៖

១. សេចក្តីសម្រេចដែលរងការជំទាស់នេះ ផ្តល់ការសំអាងហេតុផ្នែកច្បាប់សម្រាប់ការសម្រេចដោយផ្ទាល់មាត់មួយចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ដោយបានបដិសេធសំណើរបស់មេធាវីការពារក្តីសុំថតវីដេអូលោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងអនុស្សរណៈចុះថ្ងៃ

---

[1] សារអេឡិចត្រូនិពីអង្គជំនុំជម្រះតុលាការកំពូលទៅកាន់ក្រុមមេធាវីការពារក្តី អៀង សារី មានចំណងជើងថា “កម្មវត្ថុ៖លិខិតមកពីក្រុមមេធាវីការពារក្តី អៀង សារី ស្នើសុំការបញ្ជាក់, ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣” ។ “តាមដែលក្រុមមេធាវីការពារក្តីរបស់លោកអាចដឹងថាអង្គជំនុំជម្រះតុលាការកំពូល អាចនឹងចាត់ការលើបណ្តឹងសាទុក្ខដែលមិនទាន់សម្រេចរបស់ក្រុមលោកមុនពេលដែលអង្គជំនុំជម្រះតុលាការកំពូលទទួលបណ្តឹងសាទុក្ខដែលក្រុមរបស់លោកនឹងដាក់នៅពេលខាងមុខនេះ និងទឡ្ហីករណ៍ដែលមាននៅក្នុងបណ្តឹងសាទុក្ខនោះ ខ្ញុំសូមឲ្យលោកដាក់ការជូនដំណឹង ឬបណ្តឹងសាទុក្ខ ឬការបង្ហាញជាផ្លូវការមួយចំនួនអំពីចេតនារបស់លោកក្នុងការប្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ របស់អង្គជំនុំជម្រះសាលាដំបូងដោយសារតែអំណះអំណាងមិនច្បាស់លាស់ (ដូចដែលលោកបានលើកឡើងក្នុងលិខិតរបស់លោក) និងបានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលរង់ចាំរហូតដល់ពេលដែលមានព័ត៌មានពេញលេញអំពីបណ្តឹងសាទុក្ខនោះ ដើម្បីឲ្យអង្គជំនុំជម្រះតុលាការកំពូលអាចពិចារណាដោះស្រាយបណ្តឹងសាទុក្ខទាំងពីរនោះរួមគ្នាតែម្តង”។

[2] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី សុំថតវីដេអូ ឬខ្សែអាត់ អៀង សារី ក្នុងបន្ទប់រង់ចាំ, ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣, ឯកសារ E254/3 ។

[3] បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសិទ្ធិរបស់គាត់ក្នុងការមានវត្តមានក្នុងបន្ទប់សវនាការ និងរារាំងមិនឲ្យគេថតវីដេអូរូបគាត់ក្នុងបន្ទប់រង់ចាំ, ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ E238/9/1/1, សហព្រះរាជអាជ្ញា បានដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខ (E238/9/1/2) ដែលចម្លើយតបនោះមេធាវីការពារក្តីបាន ដាក់ការឆ្លើយតប(E238/9/1/3)។

ទី១២ ខែធ្នូ ឆ្នាំ២០១២ បញ្ជាមេធាវីការពារក្តីឲ្យបញ្ឈប់ការថតខ្សែអាត់លោក អៀង សារី និងឲ្យដាក់សារណាទាក់ទិននឹងសិទ្ធិរបស់ខ្លួនចំពោះការថតខ្សែអាត់ និង/ការថតគាត់ដោយវិដេអូ[4]។

២. បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់របស់ខ្លួននៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ (ដោយមិនបានផ្តល់ការសំអាងហេតុផ្នែកច្បាប់) លោក អៀង សារី បានដាក់បណ្តឹងសារទុក្ខមួយ (E238/9/1/1) ដែលបច្ចុប្បន្ននេះស្ថិតនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[5]។ បណ្តឹងសារទុក្ខនេះគ្របដណ្តប់លើបញ្ហាជាច្រើន ដែលមាននៅក្នុងសេចក្តីសម្រេចរងការជំទាស់នេះ។

៣. មេធាវីការពារក្តីស្នើសុំឲ្យមានការបញ្ជាក់ពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូល ថាតើវិធីរបៀបណាដែលល្អបំផុត ដើម្បីចាត់និតីវិធីទាក់ទងនឹងដីកាដែលរងការជំទាស់នេះ។ ថាតើត្រូវដាក់បណ្តឹងសារទុក្ខបន្ថែមលើបណ្តឹងសារទុក្ខដែលមិនទាន់ដោះស្រាយ ឬដាក់បណ្តឹងសារទុក្ខដោយឡែក[6]។

៤. មន្ត្រីច្បាប់/ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល បង្គាប់ឲ្យមេធាវីការពារក្តីដាក់បណ្តឹងសារទុក្ខដោយឡែក ជាជាងដាក់បណ្តឹងសារទុក្ខបន្ថែមលើបណ្តឹងសារទុក្ខដែលមិនទាន់ដោះស្រាយ[7]។

៥. ដោយសារបញ្ហាដែលលើកឡើងនៅក្នុងបណ្តឹងសារទុក្ខទាំងពីរនេះ មានទំនាក់ទំនងគ្នាទៅវិញទៅមក ដើម្បីប្រសិទ្ធិភាពតុលាការ មេធាវីការពារក្តីស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះតុលាការកំពូលដោះស្រាយបណ្តឹងសារទុក្ខទាំងពីរនេះជាទម្រង់រួមគ្នា ។ ហេតុនេះ មេធាវីការពារក្តីស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះតុលាការកំពូលលើកពេលការពិភាក្សាសម្រេច លើបណ្តឹងសារទុក្ខដែល

---

[4] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ៦, សូមមើលផងដែរដីកាបញ្ជាឲ្យដាក់សារណា, ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២, E254។

[5] បណ្តឹងសាទុក្ខនេះត្រូវបានដាក់នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២។ កសព បានដាក់ការឆ្លើយតបទៅកាន់បណ្តឹងសាទុក្ខនេះ (E238/9/1/2) ដែលចម្លើយតបនោះមេធាវីការពារក្តីបានដាក់ការឆ្លើយតប(E238/9/1/3)។

[6] លិខិតមកពីក្រុមមេធាវីការពារក្តី អៀង សារី ទៅកាន់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូលមានចំណងជើង សំណើសុំការបញ្ជាក់ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី សុំថតវីដេអូ និង/ឬថតសម្លេង អៀង សារី ក្នុងបន្ទប់រង់ចាំ(E254/3) , ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣។

[7] សារអេឡិចត្រូនិចពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូលទៅកាន់ ក្រុមមេធាវីការពារក្តី អៀង សារី ដែលមានចំណងជើងថា៖ លិខិតពីក្រុមមេធាវីការពារក្តី អៀង សារី សុំការបញ្ជាក់, 23 January 2013 ។

មិនទាន់ដោះស្រាយ រហូតដល់បណ្តឹងសារទុក្ខនេះត្រូវបានដាក់[8]។

សូមលោក/លោកស្រីចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលទទួលយកការជូនដំណឹងដោយការគោរព ។

______________ ______________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តី អៀង សារី

ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី**២៥** ខែ **មករា ឆ្នាំ ២០១៣**

---

[8] មេធាវីការពារក្តីយល់ឃើញថាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនក្នុងការដាក់បណ្តឹងសាទុក្ខនេះគឺវិធាន១០៤(៤)(ខ) ដែលអនុលោមតាមវិធាន១០៧ (២)បណ្តឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈ ពេលវេលាកំណត់នៃការដាក់ឯកសាររយៈពេល១៥ថ្ងៃ ។ ដោយសារតែ អវតក ត្រូវឈប់សម្រាកនៅថ្ងៃទី១ និង ទី៤ខែកុម្ភៈ ដើម្បីចូលរួមកាន់ទុកផ្លូវការលើកទី២ ដល់សម្តេចព្រះនរោត្តមសីហនុ ដូច្នេះពេលវេលាកំណត់ក្នុងការដាក់ឯកសារចំពោះបណ្តឹងសាទុក្ខនេះគឺនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣។